# ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម




ឆ្នាំទី៣១ លេខ៧៤៤ ខែកញ្ញា ឆ្នាំ២០២៤

# មាតិកា


## ០១ ស្ថិតិពាណិជ្ជកម្ម

១.១. សន្ទស្សន៍ថ្លៃទំនិញនៅលើទីផ្សាររាជធានីភ្នំពេញប្រចាំខែកញ្ញា ឆ្នាំ២០២៤.....................................០១
១.២. ការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម.......................................................................................០៣
១.៣. ការចុះបញ្ជីម៉ាកពាណិជ្ជនាម.............................................................................................០៥
១.៤. វិស័យនាំចេញរបស់កម្ពុជា...............................................................................................០៧
១.៥. តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗលើទីផ្សារអន្តរជាតិប្រចាំខែកញ្ញា ឆ្នាំ២០២៤..........................១១

## ០២ អត្ថបទស្រាវជ្រាវ

វិស័យស្រូវអង្ករកម្ពុជាឆ្នាំ២០២៤៖ .....................................................................................១៦

## ០៣ ព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម

សកម្មភាពថ្នាក់ដឹកនាំ.......................................................................................................១៨

## ០៤ ព័ត៌មានទីផ្សារអន្តរជាតិ

ការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី( ADB )អំពីកំនើនសេដ្ឋកិច្ចបណ្តាប្រទេសអាស៊ាន ឆ្នាំ២០២៤៖....២១

# ១-ស្ថិតិពាណិជ្ជកម្ម

## ◆ ១.១ សន្ទស្សន៍ថ្លៃទំនិញ នៅលើទីផ្សាររាជធានីភ្នំពេញ៖

តាមដានជាប្រចាំនូវថ្លៃទំនិញប្រើប្រាស់សំខាន់ៗ ដើម្បីកំណត់ពិដានថ្លៃលក់រាយនៅលើទីផ្សាររាជធានីភ្នំពេញ ប្រចាំខែកញ្ញា ឆ្នាំ២០២៤ ដូចជា៖(នៅលើទីផ្សារធំថ្មី, កណ្ដាល, ច្បារអំពៅ, ដើមគរ, និងផ្សារអូរឫស្សី)។

- តារាងប្រៀបធៀបសន្ទស្សន៍តម្លៃទំនិញប្រចាំជីវភាពនៅលើទីផ្សារ (ឯកតា៖ គិតជារៀល)

| ទំនិញ | ឯកតា | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| អង្ករផ្កាម្លិះ | គីឡូ/រៀល | 3,850 | 3,800 | -50 | ▼ 0.01 |
| អង្ករនាងមិញ | គីឡូ/រៀល | 3,000 | 3,000 | - | - |
| សាច់គោ | គីឡូ/រៀល | 38,500 | 38,500 | - | - |
| សាច់ជ្រូក | គីឡូ/រៀល | 20,000 | 20,000 | - | - |
| សាច់មាន់ | គីឡូ/រៀល | 26,500 | 26,500 | - | - |
| ត្រីរស់ស្រស់ | គីឡូ/រៀល | 12,500 | 13,000 | 500 | ▲ 0.04 |

- តម្លៃអង្ករ៖ តម្លៃអង្ករលក់នៅលើទីផ្សារទាំង៥ ក្នុងរាជធានីភ្នំពេញ សម្រាប់ខែសីហា ប្រៀបធៀបទៅនឹងខែកញ្ញា ឆ្នាំ២០២៤ នេះឃើញថាតម្លៃអង្ករផ្កាម្លិះមានការថយចុះ ០,០១% និងអង្ករនាងមិញមានតម្លៃថេរ។
- តម្លៃម្ហូបអាហារ៖ តម្លៃម្ហូបអាហារ នៅលើទីផ្សារទាំង៥ក្នុងរាជធានីភ្នំពេញ សម្រាប់ខែសីហា បើធៀបទៅនឹងខែកក្កដា ឆ្នាំ២០២៤ ពុំមានការប្រែប្រួលទៅលើមុខទំនិញដូចជា៖ សាច់គោមានតម្លៃថេរ សាច់ជ្រូកមានតម្លៃថេរ សាច់មាន់មានតម្លៃថេរ និងត្រីរស់ស្រស់តម្លៃកើន ០,០៤%។
- រីឯសេចក្តីសំរេចរបស់ឥណ្ឌា បានធ្វើឲ្យប្រភពផ្គត់ផ្គង់អង្ករកើនឡើងយ៉ាងគំហក់ ធ្វើឲ្យអ្នកទិញស្ថិតក្នុងកាលៈទេសៈគិតពិចារណាអំពីស្ថានភាពប្រភពផ្គត់ផ្គង់។ បើតាមឈ្មួញអង្ករវៀតណាមបានឲ្យដឹងថា បញ្ហានេះបានបង្កការពិបាកដល់វៀតណាម ក្នុងការសំរេចផែន ការនាំចេញអង្ករឲ្យបានចំនួន ៨លានតោននៅក្នុងឆ្នាំ២០២៤នេះ។ បើតាមឈ្មួញអង្ករថៃ បានឲ្យដឹងថា តម្លៃអង្ករនាំចេញរបស់ប្រទេស បានដាំក្បាលចុះ ខណៈដែលអ្នកទិញរង់ចាំអ្នកនាំចេញធ្វើការបញ្ចុះតម្លៃ ក្រោយពីឥណ្ឌាលប់ចោលច្បាប់ហាមនាំចេញអង្ករ ហើយតម្លៃអង្ករក្នុងស្រុកមានស្ថេរភាព និងព្រមពេលដែលប្រភពផ្គត់ផ្គង់សំបូរបែប។

ប្រភព៖ Webside vinanet



- **តម្លៃប្រេងឥន្ធនៈ**

តារាងប្រៀបធៀបសន្ទស្សន៍តម្លៃប្រេងឥន្ធនៈនៅលើទីផ្សារ

(ឯកតា៖ គិតជារៀល)

| ទំនិញ | ឯកតា | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| សាំងស៊ុបពែ | លីត្រ/រៀល | 4,700 | 4,550 | -150 | ▼ 0.03 |
| សាំងធម្មតា | លីត្រ/រៀល | 4,100 | 3,850 | -250 | ▼ 0.06 |
| ប្រេងម៉ាស៊ូត | លីត្រ/រៀល | 4,000 | 3,650 | -350 | ▼ 0.09 |
| ហ្គាស | ១៥គីឡូ/រៀល | 68,000 | 68,000 | - | - |







- ប្រេងឥន្ធនៈ៖ តម្លៃប្រេងឥន្ធនៈនៅបណ្តាស្ថានីយ៍ក្រុមហ៊ុនទាំង១០ របស់កម្ពុជាដូចជា ក្រុមហ៊ុនកម្ពុជាតេលា សូគីមិច ភីធីធី តូតាល់ ឈេហ្វរ៉ុន សាវីម៉ិច ប៊ីវីអឹម អិលអេចអរ ក្រុមហ៊ុនប៉ាប៉ា និងលឹម ឡុង ក្នុងបណ្តារាជធានីភ្នំពេញ សម្រាប់ខែកញ្ញា ធៀបទៅនឹងខែកក្កដា ឆ្នាំ២០២៤ តម្លៃសាំងស៊ុបពែបានថយ០,០៣%, សាំងធម្មតាបានថយ០,០៦% និងប្រេងម៉ាស៊ូតបានថយ ០,០៩% និងតម្លៃហ្គាសមានតម្លៃថេរ។
- តាមព័ត៌មានបានឲ្យដឹងថាបណ្តាប្រទេសនាំចេញ និងសម្ព័ន្ធមិត្ត ដែលហៅកាត់ថា OPEC+ និងបន្តផែនការបង្កើនបរិមាណប្រេងផលិតថែមចំនួន ១៨០០០០ធុង/ថ្ងៃ ដែលនឹងអនុវត្តបីខែធ្នូ ឆ្នាំ២០២៤តទៅ។ ដោយឡែកនៅអាម៉េរិក ក្រុមហ៊ុនធ្វើអាជីវកម្មប្រេង បានចាប់ផ្តើមសកម្មភាពឡើងវិញនៅតំបន់ឈូងសមុទ្រមិចស៊ិក ក្រោយពីព្យុះ Helene បោកបក់លើរដ្ឋ Florida គឺជាព្យុះធំទី៧ បានជះឥទ្ធិពលដល់តម្រូវការប្រេងនៅរដ្ឋនេះដែលជាទីកន្លែងប្រើប្រាស់ប្រេងច្រើនលេខ៣ ប្រចាំប្រទេស។

ប្រភព៖ Website Vinanet

## ១.២ ការចុះបញ្ជីសហគ្រាសពាណិជ្ជកម្ម

- តារាងប្រៀបធៀបចំនួនក្រុមហ៊ុន ដែលបានចុះបញ្ជីពាណិជ្ជកម្មក្នុងខែកញ្ញា ធៀបទៅនឹងខែសីហា ឆ្នាំ២០២៤

(ឯកតា៖ ចំនួនក្រុមហ៊ុន)

| ប្រភេទក្រុមហ៊ុន | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| **ករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម(ថ្មី)** | | | | |
| ក្រុមហ៊ុនមូលធន | 469 | 523 | 54 | ▲ 0.12 |
| ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 2 | 3 | 1 | ▲ 0.50 |
| សហគ្រាសឯកបុគ្គល | 411 | 430 | 19 | ▲ 0.05 |
| **ករណីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក** | | | | |
| លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | 3 | 5 | 2 | ▲ 0.67 |
| លិខិតអនុញ្ញាតសហគ្រាសឯកបុគ្គល | 1 | - | -1 | ▼ 1.00 |
| អាជ្ញាបណ្ណ | 2 | 2 | - | - |
| **ករណីស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម** | | | | |
| ក្រុមហ៊ុនមូលធន | 146 | 138 | -8 | ▲ 0.05 |
| ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 3 | 6 | 3 | ▲ 1.00 |
| សហគ្រាសឯកបុគ្គល | 26 | 20 | -6 | ▼ 0.23 |
| **ករណីស្នើសុំចុះបញ្ជីកែប្រែ** | | | | |
| កែប្រែប្ដូរភាគហ៊ុន បន្ថយបង្កើនដើមទុន | 209 | 222 | 13 | ▲ 0.06 |
| ការកែប្រែផ្សេងៗ (អភិបាល កម្មវត្ថុ .....) | 980 | 1,033 | 53 | ▲ 0.05 |
| ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | 36 | 60 | 24 | ▲ 0.67 |
| ការកែប្រែសហគ្រាសឯកបុគ្គល | 59 | 67 | 8 | ▲ 0.14 |

## ក្រាហ្វិកករណីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម(ថ្មី)




## ក្រាហ្វិកករណីស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក




## ក្រាហ្វិកករណីស្នើសុំលុបឈ្មោះ




## ក្រាហ្វិកស្នើសុំចុះបញ្ជីកែប្រែ



## ១.៣ ការចុះបញ្ជីម៉ាកពាណិជ្ជនាមៈ

- តារាងប្រៀបធៀបចំនួនម៉ាកពាណិជ្ជនាមដែលបានចុះបញ្ជីនៅក្នុងខែកញ្ញា ធៀបទៅនឹងខែសីហា ឆ្នាំ២០២៤

(ឯកតា៖ គិតជាចំនួនម៉ាក)

| ការផ្តល់សេវាផ្សេងៗ ពាក់ព័ន្ធ និងកិច្ចការពារម៉ាក | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| **ការចុះបញ្ជីម៉ាក** (Registration) | | | | |
| ក្នុងស្រុក | 179 | 230 | 51 | ▲ 0.28 |
| ក្រៅស្រុក | 208 | 251 | 43 | ▲ 0.21 |
| ការបដិសេធចុងក្រោយ និងបោះបង់ចោល | 67 | 68 | 1 | ▲ 0.01 |
| ការស្នើផ្លាស់ប្តូរម៉ាក | 16 | 17 | 1 | ▲ 0.06 |
| ការស្នើផ្លាស់ប្តូរទំនិញ រឺសេវា | - | 4 | 4 | ▲ 100.00 |
| ការស្នើផ្លាស់ប្តូរឈ្មោះអ្នកស្នើសុំ | - | 2 | 2 | ▲ 100.00 |
| ការស្នើផ្លាស់ប្តូរអាសយដ្ឋាន | - | 2 | 2 | ▲ 100.00 |
| ការស្នើផ្លាស់ប្តូរសុំពន្យារពេល | 23 | 82 | 59 | ▲ 2.57 |
| **ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ** (Madrid system) | | | | |
| សុំចុះបញ្ជីម៉ាកពីប្រទេសហត្ថលេខីតាមប្រព័ន្ធចុះបញ្ជីម៉ាកអន្តរជាតិ | 312 | 335 | 23 | ▲ 0.07 |
| ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ(Madrid system) | 325 | 283 | -42 | ▼ 0.13 |
| ការផ្លាស់ប្តូរផ្សេងៗតាមប្រព័ន្ធអន្តរជាតិ (Madrid system) | 139 | 141 | 2 | ▲ 0.01 |

## ក្រាហ្វិកការចុះបញ្ជីម៉ាកពាណិជ្ជនាម ( Registration )




## ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ ( Madrid system )



## ១.៤ វិស័យនាំចេញរបស់កម្ពុជា

- **ការនាំចេញផលិតផលពីកម្ពុជា ទៅបណ្តាប្រទេសក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**( Cambodian Export Under FTA GSP and MFN Scheme )

តារាងប្រៀបធៀបតម្លៃផលិតផលនាំចេញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

( ឯកតា៖ ដុល្លារអាមេរិក )

| ប្រភេទទំនិញ | ខ្នាត | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| សំលៀកបំពាក់ | DOZ | 791,329,742 | 816,508,927 | 25,179,185 | ▲ 0.03 |
| វាយនភ័ណ្ឌ | N/A | 8,557,095 | 5,761,157 | -2,795,938 | ▼ 0.33 |
| ស្បែកជើង | PRS | 143,021,150 | 134,202,392 | -8,818,758 | ▼ 0.06 |
| កាបូបធ្វើដំណើរ | DOZ | 164,472,283 | 148,711,450 | -15,760,833 | ▼ 0.10 |
| កង់ | SET | 34,936,528 | 30,298,298 | -4,638,230 | ▼ 0.13 |
| អង្ករ | N/A | 87,152,216 | 134,449,351 | 47,297,135 | ▲ 0.54 |
| ទំនិញកសិកម្ម | - | 118,835,699 | 106,352,321 | -12483,378 | ▼ 0.11 |
| ផលិតផលផ្សេងៗ | N/A | 831,545,380 | 779,368,431 | -52,176,949 | ▼ 0.06 |
| **សរុបរួម** | | **2,179,850,093** | **2,155,652,327** | **-24,197,766** | ▼ **0.01** |

- ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបានក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ក្រាហ្វិកតម្លៃផលិតផលនាំចេញពីកម្ពុជាទៅបណ្ដាប្រទេស ក្រោមប្រព័ន្ធ អនុគ្រោះពាណិជ្ជកម្ម និងពាណិជ្ជកម្មសេរី លើទីផ្សារពិភពលោក






- **ប្រទេសនាំចេញទំនិញពីកម្ពុជា ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី**( Cambodian Export Under FTA GSP and MFN Scheme )

តារាងប្រៀបធៀបប្រទេសនាំចេញតម្លៃទំនិញពីកម្ពុជាទៅបណ្តាប្រទេស ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (ឯកតា៖ ដុល្លារអាមេរិក)

| ប្រទេស | ខែសីហា ២០២៤ | ខែកញ្ញា ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|
| អាមេរិក | 941,563,754 | 901,583,748 | -39,980,006 | ▼ 0.04 |
| អង់គ្លេស | 92,743,359 | 85,395,390 | -7347,969 | ▼ 0.08 |
| សហគមន៍អឺរ៉ុប | 295,714,440 | 317,164,495 | 21,450,055 | ▲ 0.07 |
| កាណាដា | 102,185,379 | 103,010,442 | 825.063 | ▲ 0.01 |
| អាស៊ាន | 320,295,569 | 350,951,290 | 30,655,721 | ▲ 0.10 |
| ជប៉ុន | 148,847,727 | 142,002,286 | -6845,441 | ▼ 0.05 |
| ចិន | 154,989,318 | 117,497,892 | -37,491,425 | ▼ 0.24 |
| អូស្ត្រាលី | 13,573,662 | 18,455,788 | 4,882,126 | ▲ 0.36 |
| ឥណ្ឌា | 13,519,909 | 16,454,378 | 2,934,469 | ▲ 0.22 |
| ណូវ៉ែលហ្សេឡង់ | 2,415,723 | 1,760,377 | -655,346 | ▼ 0.27 |
| អារ៉ាប៊ីសាអូឌីត | 3,166,237 | 3,164,571 | -1,666 | - |
| កូរ៉េ | 31,708,004 | 28,409,482 | -3,298,522 | ▼ 0.10 |
| បណ្តាប្រទេសផ្សេងៗក្នុងពិភពលោក | 59,127,013 | 69,802,187 | 10,675,174 | ▲ 0.18 |
| **សរុបរួម** | **2,179,850,093** | **2,155,652,326** | **-24,197,767** | ▼ **0.01** |

- ប្រភពនាយកដ្ឋាននាំចេញ នាំចូល៖ តួលេខនាំចេញនេះ ជាតួលេខដែលទទួលបាន ក្រោមការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ក្រាហ្វិកការនាំចេញរបស់កម្ពុជា






## ១.៥ តម្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ លើទីផ្សារអន្តរជាតិប្រចាំខែកញ្ញា ឆ្នាំ២០២៤

- **អង្ករ៖**

(ឯកតា៖ ដុល្លារអាមេរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| អង្ករប្រភេទបាក់5% | FOB Bangkok | 572 | 515 | -57 | ▼ 9.97 |
| អង្ករប្រភេទបាក់5% | FOB Vietnam | 574 | 542 | -32 | ▼ 5.57 |
| អង្ករប្រភេទបាក់5% | FOB India | 555 | 492 | -63 | ▼ 11.35 |
| អង្ករប្រភេទបាក់5% | FOB មីយ៉ាន់ម៉ា | 534 | 512 | -22 | ▼ 4.12 |
| អង្ករប្រភេទបាក់5% | FOB USA | 777 | 790 | 13 | ▲ 1.67 |
| អង្ករប្រភេទបាក់5% | FOB ប៉ាគីស្ថាន | 538 | 508 | -30 | ▼ 5.58 |
| អង្ករប្រភេទបាក់25% | FOB Bangkok | 522 | 490 | -32 | ▼ 6.13 |
| អង្ករប្រភេទបាក់25% | FOB Vietnam | 535 | 512 | -23 | ▼ 4.30 |
| អង្ករប្រភេទបាក់25% | FOB India | 540 | 491 | -49 | ▼ 9.07 |
| អង្ករក្រហមប្រភេទ (Hommali) 100% | FOB Bangkok | 578 | 530 | -48 | ▼ 8.30 |
| អង្ករក្រហមប្រភេទ5% | FOB India | 562 | 525 | -37 | ▼ 6.58 |
| អង្ករប្រភេទហូមមាលី (hommali)100% | FOB Bangkok | 852 | 1078 | 226 | ▲ 26.53 |
| អង្ករក្រអូប | FOB Vietnam | 667 | 678 | 11 | ▲ 1.65 |

- កត់សំគាល់៖ តម្លៃអង្ករលក់ចេញនៅទីផ្សារសំខាន់ៗនៅក្នុងខែកញ្ញា ឆ្នាំ២០២៤នេះ គឺមានការប្រែប្រួលធៀបទៅនឹង ខែសីហា ឆ្នាំ២០២៤។
- នៅក្នុងខែកញ្ញា នេះ នៅប្រទេសថៃ តម្លៃអង្ករនាំចេញបានថយចុះពី ៣២ ទៅ៥៧ដុល្លារ/តោន(FOB, Bangkok) ធៀបទៅនឹងខែសីហា ដោយអង្ករប្រភេទបាក់ ៥% លក់ចេញក្នុងតម្លៃ ៥១៥ដុល្លារ/តោន(FOB, Bangkok) និង អង្ករប្រភេទបាក់ ២៥% លក់ចេញក្នុងតម្លៃ ៤៩០ដុល្លារ/តោន(FOB, Bangkok) និងផ្ទុយទៅវិញអង្ករប្រភេទហូមមាលី ១០០% បានកើនឡើងក្នុងតម្លៃលក់ចេញ ១០៧៨ដុល្លារ/តោន(FOB, Bangkok)។

- នៅវៀតណាម តម្លៃអង្ករនាំចេញបានថយចុះពី ២៣ ទៅ៣២ដុល្លារ/តោន(FOB,កំពង់ផែក្រុងហូជីមីញ)ធៀបខែបន្ទាប់ ដោយអង្ករប្រភេទបាក់ ៥% លក់ចេញក្នុងតម្លៃ ៥៤២ដុល្លារ/តោន(FOB, Vietnam) និងប្រភេទ ២៥% លក់ចេញក្នុងតម្លៃជាមធ្យម ៥១២ដុល្លារ/តោន(FOB, កំពង់ផែក្រុងហូជីមីញ)។ ផ្ទុយទៅវិញអង្ករប្រភេទក្រអូបបានកើនឡើង ដោយលក់ចេញក្នុងតម្លៃមធ្យម ៦៧៨ដុល្លារ/តោន(FOB, កំពង់ផែក្រុងហូជីមីញ)។ នៅក្នុងខែកញ្ញានេះ តម្លៃអង្ករនាំចេញនៅទីផ្សារមានការថយចុះ ក្រោយពីប្រទេសឥណ្ឌា (ប្រទេសនាំចេញអង្ករច្រើនបំផុតលើពិភពលោក និងមានប្រជាជនចំនួន ១,៤ពាន់លាននាក់) បន្ធូរបន្ថយច្បាប់ហាមនាំចេញអង្ករ ដើម្បីបង្កើនប្រភពផ្គត់ផ្គង់ រួមទាំងកំលាំងប្រគួតប្រជែងអង្ករនៅលើទីផ្សារក្នុងតំបន់ និងពិភពលោក។ ឥណ្ឌាអនុញ្ញាតិឲ្យនាំចេញអង្ករសំរិតគ្រប់ប្រភេទក្រោយពីរយៈពេលមួយថ្ងៃកាត់បន្ថយពន្ធលើការនាំចេញពី ២០% មកនៅត្រឹម១០%។ សេចក្តីសំរេចរបស់ឥណ្ឌា បានធ្វើឲ្យប្រភពផ្គត់ផ្គង់អង្ករកើនឡើងយ៉ាងគំហក់ ធ្វើឲ្យអ្នកទិញស្ថិតក្នុងកាលៈទេសៈគិតពិចារណាអំពីស្ថានភាពប្រភពផ្គត់ផ្គង់។ បើតាមឈ្មួញអង្ករវៀតណាមបានឲ្យដឹងថា បញ្ហានេះបានបង្កការពិបាកដល់វៀតណាម ក្នុងការសំរេចផែនការនាំចេញអង្ករឲ្យបានចំនួន ៨លានតោននៅក្នុងឆ្នាំ២០២៤នេះ។ បើតាមឈ្មួញអង្ករថៃ បានឲ្យដឹងថា តម្លៃអង្ករនាំចេញរបស់ប្រទេស បានដាំក្បាលចុះ ខណៈដែលអ្នកទិញរង់ចាំអ្នកនាំចេញធ្វើការបញ្ចុះតម្លៃ ក្រោយពីឥណ្ឌាលប់ចោលច្បាប់ហាមនាំចេញអង្ករ ហើយតម្លៃអង្ករក្នុងស្រុកមានស្ថេរភាព និងព្រមពេលដែលប្រភពផ្គត់ផ្គង់សំបូរបែប។ បច្ចុប្បន្នតម្លៃអង្ករនាំចេញរបស់ប្រទេសថៃ បានធ្លាក់ថ្លៃទាបបំផុតបើគិតចាប់តាំងពីខែមិថុនា ឆ្នាំ២០២៣ ដោយសារការប្រែប្រួលនៃតម្លៃប្រាក់ Baht និងការលុបចោលច្បាប់ហាមនាំចេញអង្កររបស់ឥណ្ឌា ។
- ៥ខែ ដើមឆ្នាំ២០២៤ ការនាំចូលអង្កររបស់ប្រទេសហ្វីលីពីន ទទួលបានចំនួនជិត ២លានតោន គឺកើន ២០,៣% ធៀបរយៈពេលដូចគ្នាឆ្នាំ២០២៣។ គិតចាប់តាំងពីដើមឆ្នាំមកដល់បច្ចុប្បន្ន ក្រសួងកសិកម្មហ្វីលីពីន បានចេញច្បាប់ចំនួន ៤០៦៦ច្បាប់អនុញ្ញាតិឲ្យឈ្មួញនាំចូលអង្ករ។ វៀតណាម ជាដៃគូរភាគី នាំចេញអង្ករធំបំផុតរបស់ហ្វីលីពីនបន្ទាប់ គឺប្រទេសថៃ នាំចេញអង្ករទៅកាន់ប្រទេសហ្វីលីពីនចំនួន ៣០០២២៧,២៤តោន និងប៉ាគីស្ថានទទួលបាន ១៤៤៨៣៤,៥០តោន មីយ៉ាន់ម៉ា ៦៥០៨០តោន ហើយមួយចំនួនទៀតនាំចូលពី ប្រទេសឥណ្ឌា ចិន ជប៉ុន កម្ពុជា អ៊ីតាលី និងប្រទេសអេស្បាញ។

- **កសិផល៖**

(ឯកតា៖ដុល្លារអាម៉េរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ស្រូវសាលី | FOB USA | 201.36 | 213.11 | 11.75 | ▲ 5.84 |
| ពោត | - | 145.51 | 153.50 | 7.99 | ▲ 5.49 |
| សណ្តែកសៀង | - | 367.00 | 391.59 | 24.59 | ▲ 6.70 |
| ប្រេងដូងមិនទាន់កែច្នៃ | FOB Malaysia | 865.50 | 1053.50 | 188 | ▲ 21.72 |
| ប្រេងសណ្តែកសៀង | CIF Rotterdam | 932.54 | 932.77 | 0.23 | ▲ 0.02 |
| គ្រាប់ម្រេចខ្មៅ | FOB (V.N) | 3,610.00 | 3,530.00 | -80 | ▼ 2.22 |
| គ្រាប់ម្រេចស | FOB (V.N) | 4,505.00 | 4,415.00 | -90 | ▼ 2.00 |

| | | | | | |
|---|---|---|---|---|---|
| កាហ្វេ(ROBUSTA) | FOB New York(USA) | 4,261.00 | 4,856.00 | 595 | ▲ 13.96 |
| កាហ្វេ(ARABICA) | London | 5,451.50 | 5,926.68 | 475.18 | ▲ 8.72 |
| កប្បាសលេខ២ | FOB New York | 1,540.40 | 1,601.29 | 60.89 | ▲ 3.95 |
| កាកាវ(ដុល្លារ/តោន) | CIF New York (USA) | 7,613.00 | 8,281.00 | 668 | ▲ 8.77 |

- កត់សំគាល់៖ តម្លៃកសិផលគ្រប់ប្រភេទមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ នៅខែកញ្ញា ឆ្នាំ២០២៤នេះ។
- តម្លៃពោត៖ នៅក្នុងខែកញ្ញា នេះ តម្លៃពោតនាំចេញនៅ Chicago បានកើនឡើងជាមធ្យម ៧,៩៩ដុល្លារ/តោន (៥,៤៩%) ធៀបខែមុន ដោយលក់ចេញក្នុងតម្លៃ ១៥៣,៥០ ដុល្លារ/តោន (FOB, Chicago)។
- តម្លៃស្រូវសាលី៖ តម្លៃស្រូវសាលីនាំចេញនៅ Chicago បានកើនឡើងជាមធ្យម ១១,៧៥ដុល្លារ/តោនស្មើនឹង ៥,៨៤% ធៀបខែសីហា ដោយលក់ចេញក្នុងតម្លៃជាមធ្យម ២១៣,១១ដុល្លារ/តោន(FOB Chicago)។
- តម្លៃសណ្ដែកសៀង៖ នៅ Chicago តម្លៃសណ្តែកសៀងនាំចេញបានកើន ២៤,៥៩ដុល្លារ/តោនស្មើនឹង ៦,៧០% ដោយលក់ចេញក្នុងតម្លៃមធ្យម ៣៩១,៥៩ដុល្លារ/តោន, FOB Chicago។
- តម្លៃប្រេងដូងប្រេង៖ តម្លៃប្រេងដូងប្រេងនៅទីផ្សារប្រទេសម៉ាឡេស៊ីនៅក្នុងខែកញ្ញា ឆ្នាំ២០២៤ បានកើន ១៨៨,០០ ដុល្លារ/តោនស្មើនឹង ២១,៧២% ដោយលក់ចេញក្នុងតម្លៃមធ្យម ១០៥៣,៥០ដុល្លារ/តោន(FOB, Malaysia)។
- តម្លៃកាហ្វេ៖ នៅខែកញ្ញានេះ តម្លៃកាហ្វេនាំចេញគ្រប់ប្រភេទបានកើនឡើងធៀបទៅនឹងខែបន្ទាប់។ នៅទីផ្សារ New York តម្លៃកាហ្វេរ៉ូប៊ូស្តារលក់ចេញបានកើន ៥៩៥,០០ដុល្លារ/តោន ស្មើនឹង ១៣,៩៦% ដោយលក់ចេញក្នុងតម្លៃមធ្យម ៤.៨៥៦,០០ដុល្លារ/តោន, FOB(ទីផ្សារ New York) និងនៅក្រុងឡុងដ៍តម្លៃកាហ្វេអារ៉ាប៊ីកាលក់ចេញបានកើន ៤៧៥,១៨ដុល្លារ/តោន ស្មើនឹង ៨,៧២% ដោយលក់ចេញក្នុងតម្លៃមធ្យម ៥.៩២៦,៦៨ដុល្លារ/តោន(FOB, ទីផ្សារឡុងដុង)។ តាមព័ត៌មានបានឲ្យដឹងថា សកម្មភាពលក់-ដូរកាហ្វេនៅលើទីផ្សារវៀតណាមបានថយចុះដោយសារប្រភពផ្គត់ផ្គង់មានការខ្វះខាត។ តាមការព្យាករណ៍បានឲ្យដឹងថា៖ បរិមាណផលិតផលកាហ្វេក្នុងស្រុកបានថយចុះខ្លាំងនៅរដូវឆ្នាំ២០២៤-២៥ គឺទាបបំផុតក្នុងរយៈពេល១៣ឆ្នាំកន្លងមកនេះ ព្រោះតែអាកាសធាតុមិនអំណោយផលល្អ ទទួលរងនូវអាកាសធាតុ El Nino រាំងស្ងួត និង ជំងឺដង្កាត់។ នៅក្នុងរយៈពេល៩ ខែ ដើមឆ្នាំ២០២៤ វៀតណាមបាននាំចេញកាហ្វេ បានចំនួន ១,១លានតោន ទោះបីជាបរិមាណកាហ្វេនាំចេញបានថយចុះ ប៉ុន្តែបើគិតជាទឹកប្រាក់នាំចេញបានកើនឡើងដោយសារតម្លៃកើនខ្ពស់។ ដោយឡែកនៅក្នុងត្រីមាសទី៣ ឆ្នាំនេះ បរិមាណផលិតផលកាហ្វេនាំចេញទទួលបាន ២១៤៩៣៥តោន ស្មើនឹងទឹកប្រាក់ចំនួន ១,១២៣ាន់លាន ដុល្លារ ។

- **ផលិតផលឧស្សាហកម្ម៖**

(ឯកតា៖ដុល្លារអាម៉េរិក/តោន)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែកក្កដា ឆ្នាំ២០២៤ | ខែសីហា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ស្ករស | CIF London | 532.55 | 571.20 | 38.65 | ▲ 7.26 |
| កៅស៊ូប្រភេទRSS3 | FOB HCM(vn) | 2,250.00 | 2,545.00 | 295 | ▲ 13.11 |

| មុខទំនិញ | លក្ខខណ្ឌប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| កៅស៊ូប្រភេទ RSS3 | FOBBangkok | 2,400.00 | 2,605.00 | 205 | ▲ 8.54 |
| កៅស៊ូប្រភេទ RSS3 | FOB Shanghai | 2,279.00 | 2,633.52 | 354.52 | ▲ 15.56 |
| កៅស៊ូប្រភេទ RSS3 | FOB Tokyo | 2,355.00 | 2,678.30 | 323.3 | ▲ 13.73 |
| កៅស៊ូប្រភេទ SMRCV | FOB Malaysia | 1,825.00 | 2,050.00 | 225 | ▲ 12.33 |
| កៅស៊ូប្រភេទ SIR20 | FOB Indonesia | 1,795.00 | 2,000.00 | 205 | ▲ 11.42 |

- កត់សំគាល់៖ តម្លៃទំនិញឧស្សាហកម្មមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ពិសេសតម្លៃស្ករស និងតម្លៃកៅស៊ូធម្មជាតិនៅក្នុងខែកញ្ញា ឆ្នាំ២០២៤នេះ។
- តម្លៃស្ករស៖តម្លៃស្ករស៖នៅក្នុងខែកញ្ញា នេះនៅទីផ្សារឡុងដ៍តម្លៃស្ករសលក់ចេញបានកើនជាមធ្យម ៣៨,៦៥ដុល្លារ/តោន ស្មើនឹង ៧,២៦%ធៀបទៅនឹងខែមុន ដោយលក់ចេញក្នុងតម្លៃ ៥៧១,២០ដុល្លារ/តោន(FOB, ឡុងដុង)។ តម្លៃស្ករសនាំចេញ បានកើនឡើងដល់តម្លៃមួយខ្ពស់បំផុតគិតចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២៤ ដោយសារសេចក្តីព្រួយបារម្ភអំពីរដូវប្រមូលផលនឹងត្រូវបំផ្លាញដោយសារភ្លើងឆេះព្រៃ រដូវរាំងស្ងួតនៅប្រទេសប្រេស៊ីល ដែលជាប្រទេសដាំ និងផលិតស្ករ។ កត្តាខាងលើ បានបង្កើនការចំណាយច្រើនទៅលើទំនិញសព្វសារពើ ចាប់តាំងពីភេសជ្ជៈ រហូតដល់ស្ករគ្រាប់ ....។
- កៅស៊ូធម្មជាតិ៖ តម្លៃកៅស៊ូធម្មជាតិប្រភេទ RSS2 លក់ចេញនៅទីផ្សារតូក្យូប្រទេសជប៉ុននៅក្នុងខែកញ្ញា នេះ បានកើនឡើងជាមធ្យម ៣២៣,៣ដុល្លារ/តោន(១៣,៧៣%)ធៀបខែមុន ដោយលក់ចេញក្នុងតម្លៃមធ្យម ២.៦៧៨,៣០ ដុល្លារ/តោន(FOB, តូក្យូ)។ តម្លៃកៅស៊ូនាំចេញនៅទីផ្សារជប៉ុន បានកើនឡើង ដោយសារប្រាក់យេនជប៉ុនធ្លាក់ថ្លៃធៀបទៅនឹងរូបិយបណ្ណមានតម្លៃផ្សេងទៀត ដូចជាដុល្លារអាមេរិក និងការផ្លាស់ប្តូរទស្សនៈរបស់ឈ្មួញ ដោយពីប្រទេសចិន បានប្រកាសផែនការជំរុញកំនើនសេដ្ឋកិច្ចឡើងវិញ។ នៅប្រទេសថៃ (ប្រទេសផលិតកៅស៊ូច្រើន)បើតាមមជ្ឈមណ្ឌលព្យាករណ៍អាកាសធាតុ បានឲ្យដឹងថា៖ នៅក្នុងកញ្ញា និងតុលានឹងមានជំនន់ទឹកភ្លៀងនៅតំបន់ដាំកៅស៊ូមួយចំនួន ។

- **ប្រេងឥន្ធនៈ:**

(ឯកតា៖ ដុល្លារអាម៉េរិក/ធុង)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| ប្រេងឆៅBrent | FOB (New York) | 80.14 | 71.98 | -8.16 | ▼ 10.18 |
| ប្រេង WTI | - | 76.02 | 68.18 | -7.84 | ▼ 10.31 |
| ហ្គាសGas($/mmbtu | F0B (VN) | 2.14 | 2.90 | 0.76 | ▲ 35.51 |

- កត់សំគាល់៖ នៅក្នុងខែកញ្ញា ឆ្នាំ២០២៤នេះ តម្លៃប្រេងឥន្ធនៈមានការប្រែប្រួលទៅតាមប្រភេទនីមួយៗ និងជាពិសេសតម្លៃប្រេងឆៅ។
- តម្លៃប្រេងឆៅ(Brent)៖នៅទីផ្សារក្រុងញ៉ូយកតម្លៃប្រេងឆៅ Brent បានថយចុះ ៨,១៦ដុល្លារ/ធុង(១០,១៨%) ដោយលក់ចេញក្នុងតម្លៃជាមធ្យម ៧១,៩៨ដុល្លារ/ធុង(FOB, London)។ តាមព័ត៌មានបានឲ្យដឹងថាបណ្តាប្រទេសនាំចេញ និងសម្ពន្ធមិត្ត ដែលហៅកាត់ថា OPEC+ និងបន្តផែនការបង្កើនបរិមាណប្រេងផលិតថែមចំនួន ១៨០០០០ធុង/ថ្ងៃ ដែលនឹងអនុវត្តបីខែធ្នូ ឆ្នាំ២០២៤តទៅ។ ដោយឡែកនៅអាម៉េរិក ក្រុមហ៊ុនធ្វើអាជីវកម្មប្រេងបានចាប់ផ្តើមសកម្មភាពឡើងវិញនៅតំបន់ឈូងសមុទ្រមិចស៊ិក ក្រោយពីព្យុះ Helene បោកបក់លើរដ្ឋ Florida គឺជាព្យុះធំទី៧ បានជះឥទ្ធិពលដល់តម្រូវការប្រេងនៅរដ្ឋនេះដែលជាទីកន្លែងប្រើប្រាស់ប្រេងច្រើនលេខ៣ ប្រចាំប្រទេស។

- **លោហៈ:**

(ឯកតា៖ ដុល្លារអាម៉េរិក)

| មុខទំនិញ | លក្ខខណ្ឌ ប្រគល់-ទទួល | ខែសីហា ឆ្នាំ២០២៤ | ខែកញ្ញា ឆ្នាំ២០២៤ | កើន(+) ថយ(-) | ភាគរយ (%) |
|---|---|---|---|---|---|
| មាស ( $ / ounce ) | Hong Kong | 2,544.00 | 2,668.10 | 124.10 | ▲ 4.88 |
| មាស ( $ / ounce ) | London | 2,517.18 | 2,658.24 | 141.06 | ▲ 5.60 |
| មាស ( $ / ounce ) | New York | 2,575.00 | 2,695.50 | 120.5 | ▲ 4.68 |
| Platinum($/ounce) | - | 979.00 | 954.00 | -25 | ▲ 2.55 |
| Palladium($/ounce | New York | 941.15 | 31.82 | 1.94 | ▲ 6.49 |
| ប្រាក់($/troy ounce) | London | 29.88 | 30.50 | 1.45 | ▲ 4.99 |

(ឯកតា៖ ដុល្លារអាម៉េរិក)

| | | | | | |
|---|---|---|---|---|---|
| ប្រាក់($/troy ounce) | New York | 29.05 | 9,982.00 | 738 | ▲ 7.98 |
| ស្ពាន់($/tons) | FOB London | 9,244.00 | 2,646.50 | 189 | ▲ 7.69 |
| អាលុយមីញ៉ូម(Al) ($/tons) | - | 2,457.50 | 3,089.50 | 211.5 | ▲ 7.35 |
| ស័ង្កសី(Zinc)($/tons) | FOB London | 2,878.00 | 32,913 | 568 | ▲ 1.76 |
| សំណប៉ាហាំង(Tin) ($/tons) | - | 32,345.00 | 17,390.00 | 973 | ▲ 5.93 |
| នីកែល(Nickel)(ដុល្លារ/T | - | 16,417.00 | 2,646.50 | 189 | ▲ 7.69 |

- កត់សំគាល់៖ តម្លៃទំនិញលោហៈ មានការប្រែប្រួលទៅតាមប្រភេទនីមួយៗ ជាពិសេសតម្លៃមាស។ នៅលើទីផ្សារអន្តរជាតិ តម្លៃមាសបានកើនឡើងធៀបទៅនឹងខែមុន នៅទីក្រុងឡុងដ៍តម្លៃមាសលក់ចេញបានកើន ១៤១,០៦ដុល្លារ/Ounce ស្មើនឹង ៥,៦០% ដោយលក់ចេញក្នុងតម្លៃ ជាមធ្យម២.៦៥៨,២៤ USD/Ounce និងនៅហុងកុង តម្លៃមាសលក់ចេញកើន១២៤,១០ដុល្លារ/ធុង ស្មើនឹង ៤,៨៨% ដោយលក់ចេញក្នុងតម្លៃ ២.៦៦៨,១០USD/Ounce។
  ប្រភព៖ (Website Vinanet)

# ២. អត្ថបទស្រាវជ្រាវ

## ▲ វិស័យស្រូវអង្ករកម្ពុជាឆ្នាំ២០២៤៖

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ សហពន្ធ័ស្រូវអង្ករកម្ពុជា បានរៀបចំកម្មវិធីវេទិកាស្រូវអង្ករកម្ពុជាលើកទី៧ ឆ្នាំ២០២៤ ក្រោមប្រធានបទ “ការប្រែក្លាយខ្សែច្រវ៉ាក់ផ្គត់ផ្គង់ វិស័យស្រូវអង្ករកម្ពុជា ឲ្យកាន់តែមានភាពធន់ បរិយាបន្ន និងនិរន្តរភាព“ ដើម្បីផ្សព្វផ្សាយអំពីសក្តានុពល នៃវិស័យស្រូវអង្ករកម្ពុជា ទៅកាន់ពិភពលោកតាមរយៈការបង្ហាញអំពីសមត្ថភាពផលិតកម្មស្រូវ ការកិនកែច្នៃ និងភាពប្រជែងឈ្នះផ្សេងទៀត របស់វិស័យស្រូវអង្ករកម្ពុជា ។

ការចូលរួមបើកវេទិកាដោយ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងវត្តមានឯកអគ្គរាជទូតអូស្រ្តាលីប្រចាំកម្ពុជា។ ឧកញ៉ា សុង សារ៉ន ប្រធានក្រុមប្រឹក្សាភិបាល សហព័ន្ធស្រូវអង្ករកម្ពុជា បានថ្លែងក្នុងវេទិកាថា៖ គឺការឆ្លុះបញ្ចាំងពីកិច្ចសហប្រតិបត្តិការពីគ្រប់វិស័យ ដើម្បីធ្វើឲ្យខ្សែច្រវ៉ាក់ផលិតកម្មស្រូវអង្ករកម្ពុជា កាន់តែប្រសើរឡើងថែមទៀត។ លោកឧកញ៉ាបានឲ្យដឹងទៀតថា កម្មវិធីនេះ បានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសក្តានុពល នៃវិស័យស្រូវអង្ករកម្ពុជាទៅកាន់ពិភពលោក តាមរយៈការបង្ហាញអំពីសមត្ថភាពផលិតកម្មស្រូវ ការកិនកែច្នៃ និងភាពប្រជែងឈ្នះផ្សេងទៀតរបស់វិស័យស្រូវអង្ករកម្ពុជា ចែករំលែកដល់អង្គវេទិកា ស្តីអំពីនិន្នាការនៃទីផ្សារ ការដាំដុះ និងបច្ចេកវិទ្យាដែលពាក់ព័ន្ធដល់ការដាំដុះស្រូវ ការកិនកែច្នៃស្រូវអង្ករ ចែករំលែកដល់អង្គវេទិកាស្តីអំពីទស្សនៈវិស័យ គោលនយោបាយ និងវិធានការនានារបស់រាជរដ្ឋាភិបាល លើវិស័យស្រូវអង្ករកម្ពុជា វេទិកាសម្រាប់ពិភាក្សា ដើម្បីស្វែងរកជាតុចូល និងអនុសាសន៍នានាសម្រាប់លើកកម្ពស់វិស័យស្រូវអង្ករកម្ពុជា។ គោលបំណងធំមួយទៀត គឺការពង្រឹង និងពង្រីកខ្សែច្រវ៉ាក់ផ្គត់ផ្គង់ស្រូវអង្ករកម្ពុជាឲ្យឆ្លើយតបទៅនឹងបរិបទនៃការប្រែប្រួលបរិយាកាស និងនិន្នាការពិភពលោកលើការធ្វើឲ្យកាន់តែប្រសើរឡើងបរិស្ថាន

ការទទួលខុសត្រូវសង្គម និងអភិបាលកិច្ចល្អ ដែលជាការកម្រិត និងលក្ខខណ្ឌតម្រូវរបស់ទីផ្សារអន្តរជាតិ សម្រាប់ការនាំចេញអង្ករដែលចាប់ផ្តើមអនុវត្តន៍ សម្រាប់ទីផ្សារសហគមន៍អឺរ៉ុបពីដើមឆ្នាំ២០២៦ តទៅ។

វិស័យស្រូវអង្ករ គឺបានទទួលការយកចិត្តទុកដាក់ពីរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវកម្មវិធីគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករដែលអនុម័តដោយទីស្តីការគណៈរដ្ឋមន្រ្តី កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ក្នុងគោលបំណងជំរុញការអភិវឌ្ឍន៍វិស័យកសិកម្មឲ្យមានសន្ទុះ និងលើកកំពស់ជីវភាពប្រជាជនផងដែរ។ តាមរយៈគោលនយោបាយដ៏មានសារៈសំខាន់នេះ ផលិតកម្មស្រូវនៅឆ្នាំ២០១០-១១ មានប្រមាណតែ ៧,៣លានតោនស្រូវសើម ហើយការនាំចេញមានតែត្រឹមចំនួន ១៣ពាន់តោនអង្ករ និង ២០ពាន់តោនស្រូវ នៅក្នុងឆ្នាំ២០០៩ ប៉ុណ្ណោះ។ តាមរយៈគោលនយោបាយនេះ បានជំរុញឲ្យមានការរីកចំរើនជាបណ្តើរៗគួយ៉ាងផលិតកម្មស្រូវ និងបានកើនឡើង ១២,៤៥លាន តោនស្រូវសើម នៅក្នុងឆ្នាំ២០២២-២៣ និងបាននាំចេញនូវអង្ករ ៦៥៦ពាន់តោន ស្មើនឹងទឹកប្រាក់ ៤៦៦លានដុល្លារអាម៉េរិក និងបាននាំចេញនូវស្រូវបានចំនួន ៤,៣៩លានតោន ស្មើនឹង ១,៣២ពាន់លានដុល្លារអាម៉េរិក។ គិតជារួមនៅក្នុងឆ្នាំ២០២៣ កម្ពុជាបាននាំចេញស្រូវ អង្ករ គិតជាទឹកប្រាក់សរុបចំនួន ១,៧៩ពាន់លានដុល្លារអាម៉េរិក។

ក្នុងរយៈពេល៨ខែ ដើមឆ្នាំ២០២៤ នេះ ការនាំចេញអង្ករបានចំនួន ១១២ពាន់តោន និងការនាំចេញស្រូវ ៣,៣ លានតោន ហើយអ្វីដែលរិតតែប្រសើរជាងនេះក្នុងរយៈពេល១២ខែ បើគិតពីខែសីហា ឆ្នាំ២០២៣ ដល់ខែសីហា ឆ្នាំ ២០២៤ នេះ រាជរដ្ឋាភិបាលនីតិកាលទី៧ វិស័យស្រូវអង្ករកម្ពុជាមានការរីកចំរើនគួរឲ្យកត់សំគាល់ និងមានការនាំចេញអង្ករសរុបចំនួន ៧០៥.៦៣៨តោន និងនាំចេញស្រូវចំនួន ៥.០២៧.៣៦៩តោន។ ក្រោមការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសេនាធិការដូចជា៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើការអភិវឌ្ឍន៍ពូជស្រូវ បច្ចេកទេសដាំដុះ ក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា និងនវានុវត្តន៍ នៅលើស្តង់ដា និងកែច្នៃ ក្រសួងពាណិជ្ជកម្មលើការធ្វើពិពិធកម្មទីផ្សារ ផ្សព្វផ្សាយ និងចូលរួមពីស្ថាប័ននានា ដែលជាដៃគូអភិវឌ្ឍន៍ របស់បណ្តាប្រទេសជាមិត្ត និងស្ថាប័នអន្តរជាតិ បានជួយលើកកំពស់វិស័យស្រូវអង្ករកម្ពុជា ដោយបានពង្រីកនូវគោលដៅទីផ្សារនាំចេញដែលមានការកើនឡើងពី ៣៥គោលដៅ នៅក្នុងឆ្នាំ២០១០ រហូតដល់ទី ១២១គោលដៅ នៅក្នុងឆ្នាំ២០២៣ និងធ្វើឲ្យវិស័យស្រូវអង្ករកម្ពុជាទទួលស្គាល់ទូទាំងពិភពលោក តាមរយៈការទទួលបាននូវពានរង្វាន់អង្ករល្អដាច់គេ ប្រភេទផ្ការំដួលចំនួន ៥ដងជាប់ៗគ្នា គឺនៅក្នុងឆ្នាំ២០១២ ២០១៣ ២០១៤ ២០១៨ និងឆ្នាំ២០២២ និងពានរង្វាន់អង្ករមាសពូជសែនក្រអូបពីប្រទេសចិនឆ្នាំ២០២៣។

ដើម្បីជួយដល់វិស័យស្រូវអង្ករ អោយកាន់តែមានភាពប្រកួតប្រជែង រដ្ឋាភិបាលបានដាក់ចេញនូវវិធានការមួយចំនួន ដែលក្នុងនោះមានការលើកទឹកចិត្តលើវិស័យពន្ធដា ពន្ធគយលើការនាំចេញ-ចូល នូវបរិក្ខាម៉ាស៊ីនកិនស្រូវ ចាប់តាំងពីឆ្នាំ២០១១មកដល់បច្ចុប្បន្ន។ វិធានការគោលនយោបាយហិរញ្ញប្បទាន ឥណទានរបស់រាជរដ្ឋាភិបាល តាមរយៈធនាគាអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានធ្វើឲ្យវិស័យស្រូវអង្ករកម្ពុជា ជាពិសេសរោងម៉ាស៊ីនកិនស្រូវ ដែលមានលទ្ធភាពពង្រឹង និងពង្រីកសក្តានុពលរបស់ខ្លួនលើសមត្ថភាពនៃការបំពាក់ឡសំងួត ដែលអាចសំងួតបាន ៥០ពាន់តោន/ថ្ងៃ ឃ្លាំងស្តុកស្រូវចំនួន ២លានតោនក្នុងមួយវគ្គ នៃរដូវច្រូតកាត់។ បំពាក់បរិក្ខាកិនកែច្នៃអង្ករ ដែលមានភាពទំនើបដែលជាបច្ចេកវិទ្យាចុងក្រោយរបស់ពិភពលោក ដូចប្រទេសជឿនលឿននានាផងដែរ រោងម៉ាស៊ីនកិនស្រូវខ្នាតធំ និងមធ្យមនៅទូទាំងប្រទេសមានចំនួន ២៧០ទីតាំង។ ក្នុងចំនួនខាងលើមាន ៨០ទីតាំង មានសមត្ថភាព និងបរិក្ខាគ្រប់គ្រាន់ស្របទៅតាមបទដ្ឋាននាំចេញ ដែលអាចកិនបានចំនួន ១២០០តោន/ម៉ោង ស្មើនឹង ១២០០០តោន/ថ្ងៃ មូលដ្ឋាននៃការធ្វើការ ១០ម៉ោង/ថ្ងៃ។

បច្ចុប្បន្ន កម្ពុជាមានផលិផលកសិកម្មជាច្រើនប្រភេទនាំចេញទៅក្រៅប្រទេស ដូចជាសហរដ្ឋអាមេរិក និងបណ្តាប្រទេសជាច្រើននៅសហគមអឺរ៉ុប ដែលជាមោទនៈភាពរបស់កម្ពុជាក្នុងរយៈពេល ៣០ឆ្នាំកន្លងមកនេះ។ រាជរដ្ឋាភិបាល អណត្តិថ្មីក៏ដូចជាចាស់ គឺបានដាក់ចេញនូវភាពអនុគ្រោះជាច្រើន ដូចជាការលើកលែងពន្ធប្រចាំឆ្នាំសំរាប់ដីធ្វើកសិកម្ម ការលែងអាករបន្ថែមលើធ្យោយផលិត។ល។ ទន្ទឹមនេះ រដ្ឋាភិបាលក៏បានដាក់ចេញនូវអតិភាពចំនួន ៣ផងដែរ៖ ទី១ គឺការលើកស្ទួយផលិតកម្ម កសិកម្ម រកទីផ្សារ និងរក្សាលំនឹងតម្លៃផលិតផល និងតាមរយៈកម្មវិធីហិរញ្ញវត្ថុហិរញ្ញបទាន។ ទី២ ការដាក់ពង្រាយមន្រ្តីកសិកម្ម នៅតាមឃុំសង្កាត់ ដើម្បីចុះជួយកសិករផ្នែកបច្ចេកទេសនៅតាមមូលដ្ឋានភូមិឃុំ និងទី៣ ការអភិវឌ្ឍន៍កសិកម្មទំនើបដែលបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្ម ព្រមទាំងការឧបត្ថម្ភទុនពីសំណាក់រាជរដ្ឋាភិបាលផងដែរ។ កត្តាសំខាន់មួយទៀត គឺគំរោងកសាងព្រែកជីកហ្វូណន ជាគំរោងជារាសាស្រ្ត

និងភស្តុភាកម្មសំរាប់ការនាំចេញនៅក្នុងស្រុក ក៏ដូចជាក្រៅប្រទេស ជានាឲ្យវិស័យកសិកម្មទទួលបានផលប្រយោជន៍ខ្ពស់ព្រមទាំងកិច្ចសហប្រតិបត្តិរបស់ភាគីពាក់ពន្ធ័។

លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានចែករំលែកនូវអនុសាស៍ផ្ទាល់ខ្លួនដល់សហព័ន្ធស្រូវអង្ករកម្ពុជា ក្រុមហ៊ុននាំចេញ និងភាគីពាក់ពន្ធ័ទាំងអស់រួមមាន៖ ១- បន្តសហការជិតស្និទ្ធជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធ ជាពិសេសក្រុមហ៊ុនហ្វ្រីនត្រេដ ក្នុងការចូលរួមរក្សាបាននូវសន្តិសុខស្បៀង និងសម្របសម្រួលសម្រាប់ការផ្គត់ផ្គង់ និងនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិ។ ២- ចូលរួមកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មតាមបណ្តាព្រំដែនស្របច្បាប់ ប្រកបដោយក្រមសីលធម៌ និងតម្លាភាព ផ្គត់ផ្គង់អង្ករដែលមានលក្ខណៈប្រកួតប្រជែង ការពារផលប្រយោជន៍របស់គ្រប់ភាគីពាក់ព័ន្ធ បង្កើនភាពជឿជាក់ និងរក្សាបានកេរ្តិ៍ឈ្មោះអង្ករកម្ពុជានៅលើទីផ្សារជាតិ និងអន្តរជាតិ។ ៣- ចូលរួមលើកកម្ពស់ និងការពារកម្មសិទ្ធិបញ្ញា តាមរយៈការកសាង និងជំរុញផ្សព្វផ្សាយម៉ាក ជាពិសេសម៉ាកសមូហភាព និងការពង្រឹងគុណភាពអង្ករកម្ពុជា។ ៤- សហការគ្នា និងស្វែងរកមតិកែលម្អពីភាគីពាក់ពន្ធ័ និងអនុវត្តវិធានការចាំបាច់នានា ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាព រក្សាទីផ្សារដែលមានស្រាប់ និងពង្រីកទីផ្សារថ្មី។ ៥- បន្តកិច្ចសហការជាប្រចាំជាមួយអ្នកនាំចូលអង្ករទាំងអស់ ដែលជាដៃគូរធ្វើពាណិជ្ជកម្មរបស់កម្ពុជា៕

ប្រភព៖ ឯកសារស្រាវជ្រាវ

# ៣. ព័ត៌មានរបស់ក្រសួងពាណិជ្ជកម្ម

### លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ បានអញ្ជើញអម ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងពិធីលាងសាយភោជន៍ស្វាគមន៍ ដែលរៀបចំឡើងដោយឯកឧត្តម Ding Xuexiang ឧបនាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតចិន នាឱកាសនៃការចូលរួមពិព័រណ៍ចិន-អាស៊ានលើកទី២១

(ណាននីង, សាធារណរដ្ឋប្រជាមានិតចិន)៖ នាល្ងាចថ្ងៃចន្ទ ទី២៣ ខែកញ្ញា ឆ្នាំ២០២៤ នៅវិមានលីយ៉ន នាទីក្រុងណាននីង ខេត្តក្វាងស៊ី សាធារណប្រជាមានិតចិន លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ បានអញ្ជើញអម ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងពិធីលាងសាយភោជន៍ស្វាគមន៍ ដែលរៀបចំឡើងដោយ ឯកឧត្តម Ding Xuexiang ឧបនាយករដ្ឋមន្ត្រីនៃសាធារណប្រជាមានិតចិន នាឱកាសនៃការចូលរួមពិព័រណ៍ចិន-អាស៊ានលើកទី២១។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2270

### លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អញ្ជើញចូលរួមពិធីសម្ពោធស្តង់ពិព័រណ៍ពាណិជ្ជកម្មរបស់កម្ពុជា នាឱកាសព្រឹត្តិការណ៍ពិព័រណ៍ចិន-អាស៊ាន លើកទី២១ នៅទីក្រុងណាននីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន

(ណាននីង សាធារណរដ្ឋប្រជាមានិតចិន)៖ នាព្រឹកថ្ងៃអង្គារ ទី២៤ ខែកញ្ញា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិណាននីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធស្តង់ពិព័រណ៍ពាណិជ្ជកម្មរបស់កម្ពុជា នាឱកាសព្រឹត្តិការណ៍ពិព័រណ៍ចិន-អាស៊ានលើកទី២១ ក្រោមអធិបតីភាព ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2277

## លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ បានអញ្ជើញអម ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងពិធីសម្ពោធពិព័រណ៍ចិន-អាស៊ាន លើកទី២១ ក្រោមអធិបតីភាព ឯកឧត្តម Ding Xuexiang ឧបនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន និងមានការចូលរួមពីប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកអាស៊ាន ភ្ញៀវជាតិ និងអន្តរជាតិជាច្រើនរូប

(ណាននីង សាធារណរដ្ឋប្រជាមានិតចិន)៖ នាព្រឹកថ្ងៃអង្គារ ទី២៤ ខែកញ្ញា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិណាននីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាប្រធានគណៈកម្មការរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ បានអញ្ជើញអម ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងពិធីសម្ពោធពិព័រណ៍ចិន-អាស៊ាន លើកទី២១ ក្រោមអធិបតីភាព ឯកឧត្តម Ding Xuexiang ឧបនាយករដ្ឋមន្ត្រីនៃសាធារណប្រជាមានិតចិន និងមានការចូលរួមពីប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកអាស៊ាន ភ្ញៀវជាតិ និងអន្តរជាតិជាច្រើនរូប។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://www.moc.gov.kh/news/2091

## លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី២៤ និងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និងលើកទី៤៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដើម្បីទទួលស្តាប់របាយការណ៍វឌ្ឍនភាពការងារ និងពិនិត្យលើឯកសារពាក់ព័ន្ធនានាដោយមានវត្តមានអញ្ជើញចូលរួមដោយ ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ និងមន្ត្រីជំនាញរបស់ក្រសួងពាណិជ្ជកម្ម

(ភ្នំពេញ)៖ នាព្រឹកថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៤ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី២៤ និងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និងលើកទី៤៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដើម្បីទទួលស្តាប់របាយការណ៍វឌ្ឍនភាពការងារ និងពិនិត្យលើឯកសារពាក់ព័ន្ធនានាដោយមានវត្តមានអញ្ជើញចូលរួមដោយឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ និងមន្ត្រីជំនាញរបស់ក្រសួងពាណិជ្ជកម្ម។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2301

## លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអញ្ជើញដឹកនាំកិច្ចប្រជុំវឌ្ឍនភាពការងារនៃគណៈកម្មការរៀបចំព្រឹត្តិការណ៍ “អបអរសាទរខួប ២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក” ដើម្បីទទួលស្តាប់របាយការណ៍វឌ្ឍនភាពការងារ និងផ្តល់អនុសាសន៍ណែនាំ ដោយមានវត្តមានអញ្ជើញចូលរួមដោយឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ និងមន្ត្រីជំនាញរបស់ក្រសួងពាណិជ្ជកម្ម

(ភ្នំពេញ)៖ នាព្រឹកថ្ងៃចន្ទ ទី៣០ ខែកញ្ញា ឆ្នាំ២០២៤ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអញ្ជើញដឹកនាំកិច្ចប្រជុំវឌ្ឍនភាពការងារនៃគណៈកម្មការរៀបចំព្រឹត្តិការណ៍ “អបអរសាទរខួប ២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក” ដើម្បីទទួលស្តាប់របាយការណ៍វឌ្ឍនភាពការងារ និងផ្តល់អនុសាសន៍ណែនាំ ដោយមានវត្តមានអញ្ជើញចូលរួមដោយឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ និងមន្ត្រីជំនាញរបស់ក្រសួងពាណិជ្ជកម្ម។ រួមទាំងពាណិជ្ជករថៃជាច្រើនរូប។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2305

**ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ លើកទី២៩** (29th AEM-CER Consultation)

(វៀងចន្ទន៍, ឡាវ)៖ នាព្រឹកថ្ងៃសៅរ៍ ទី២១ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម តំណាងដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា បានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ លើកទី២៩ នៅរដ្ឋធានីវៀងចន្ទន៍ ប្រទេសឡាវ។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2264

**ឯកឧត្តម រដ្ឋ សារ៉ាវុធ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានចូលរួមវេទិកាពិភពលោកលើកទី១០ របស់អង្គការតំបន់សេរីពិភពលោក នៅទីក្រុងឌុយបៃ នៃប្រទេសអេមីរ៉ាតអារ៉ាប់រួម**

(ឌុយបៃ, អេមីរ៉ាតអារ៉ាប់រួម)៖ នាថ្ងៃទី២៣-២៥ ខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តម រដ្ឋ សារ៉ាវុធ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានអញ្ជើញចូលរួមវេទិកាពិភពលោកលើកទី១០ របស់អង្គការតំបន់សេរីពិភពលោក (The 10th World Free Zones Organization Congress) នៅទីក្រុងឌុយបៃ នៃប្រទេសអេមីរ៉ាតអារ៉ាប់រួម ដែលមានការអញ្ជើញចូលរួមពីតំណាងថ្នាក់ដឹកនាំនៃស្ថាប័នរដ្ឋ-ឯកជន និងបញ្ញវន្ត សរុបចំនួនប្រមាណ ២០០០នាក់ មកពីជាង ១០០ប្រទេសទូទាំងពិភពលោក ក្នុងគោលបំណងដើម្បីពិភាក្សានិងស្វែងយល់អំពីសារសំខាន់នៃតំបន់សេដ្ឋកិច្ចពិសេស ក្នុងការទាក់ទាញការវិនិយោគ ការបង្កើតការងារ និងការជំរុញនវានុវត្តន៍ ព្រមទាំងដើម្បីស្វែងរកកាលានុវត្តភាពថ្មីៗ សម្រាប់ការវិនិយោគលើ អនាគតនៃកស្តុភារកម្ម កម្មន្តសាល ថាមពល ឌីជីថល និងអនាគតនៃការស្វែងរកហិរញ្ញវត្ថុ (access to finance)។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2264

**ឯកឧត្តម ស៊ាង ថៃ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយគណៈប្រតិភូក្រុង Jiaxing ខេត្ត Zhejiang នៃសាធារណរដ្ឋប្រជាមានិតចិន**

(ភ្នំពេញ)៖ នាព្រឹកថ្ងៃពុធ ទី២៥ ខែកញ្ញា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ឯកឧត្តម ស៊ាង ថៃ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូទីក្រុង Jiaxing ខេត្ត Zhejiang នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយ លោក Sheng Quansheng អនុប្រធានគណៈកម្មាធិការទីក្រុង Jiaxing ដែលមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ និងមន្ត្រីជំនាញពាក់ព័ន្ធជាច្រើនរូប។

គោលបំណងនៃជំនួបនេះ គឺដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-ចិន ដែលបានផ្តល់ផលប្រយោជន៍យ៉ាងធំធេងដល់ការរីកចម្រើនលើគ្រប់វិស័យ។ ជាមួយគ្នានេះ គណៈប្រតិភូទីក្រុង Jiaxing មានបំណងសិក្សាស្វែងយល់ពីសក្តានុពលសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគមួយចំនួននៅកម្ពុជា ជាពិសេសថាមពលពន្លឺព្រះអាទិត្យ និងវិស័យកសិកម្ម។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2293

**ឯកឧត្តម ឡុង កែមវិចិត្រ ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ានត្រៀមសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី២៤** (Prep-SEOM for the 24th AEC Council Meeting) **នៅទីក្រុងវៀងច័ន្ទន៍ ប្រទេសឡាវ**

(វៀងច័ន្ទន៍, ឡាវ)៖ នាថ្ងៃអាទិត្យ ទី៦ ខែតុលា ឆ្នាំ២០២៤ នៅសណ្ឋាគារ Latsavong Wanda Vista ឯកឧត្តម ឡុង កែមវិចិត្រ អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ និងជាឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ានតំណាងកម្ពុជា (SEOM Lead for Cambodia) បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ានត្រៀមសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ានលើកទី២៤ (Prep-SEOM for the 24th AEC Council Meeting)។

សូមចូលអានព័ត៌មានលំអិតតាមរយៈ https://moc.gov.kh/news/2312

# ៤.ព័ត៌មានទីផ្សារអន្តរជាតិ

## ▲ ការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)អំពីកំនើនសេដ្ឋកិច្ចបណ្តាប្រទេសអាស៊ាន ឆ្នាំ២០២៤៖

តាមសេចក្តីប្រកាសនៅក្នុងខែ កក្កដា ឆ្នាំ២០២៤ របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អំពីកំណើនសេដ្ឋកិច្ចនៅបណ្តាប្រទេសអាស៊ាន ទទួលបានកំនើនខ្ពស់នៅដើមឆ្នាំនេះ ដោយសារកំលាំងគាំពារពីស្ថេរភាពនៃខឿនសេដ្ឋកិច្ចពិភពលោក។ ហើយកំណើនសេដ្ឋកិច្ចនៅតំបន់អាស៊ីអគ្នេយ៍ គឺស្ថិតក្នុងកំរិត ៤,៦% នៅក្នុងឆ្នាំ២០២៤ និង ៤,៧% នៅក្នុងឆ្នាំ២០២៥ មួយផ្នែកគឺពឹងផ្អែកលើកំលាំងស្តារឡើងវិញដ៏រឹងមាំនៃតម្រូវការក្នុងស្រុក និងពាណិជ្ជកម្មក្រៅប្រទេស។ ការស្តារឡើងវិញនៃវិស័យនាំចេញ បានជះឥទ្ធិពលសំខាន់ទៅលើសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យពាណិជ្ជកម្ម ដោយសាការបញ្ជាទិញបាន កើនឡើងដូច្នេះសកម្មភាពនាំចូល និងនាំចេញរបស់បណ្តាប្រទេសអាស៊ានមួយចំនួនមានការរីកចំរើន។ ការនាំចេញគ្រឿងអេឡិចត្រូនិចរបស់ប្រទេសហ្វីលីពីនមានចំនួន ៥៨%ម៉ាឡេស៊ី ៣១% វៀតណាម និងសឹង្ហបុរី ២៣% នៃបរិមាណសរុប។

ខឿនសេដ្ឋកិច្ចនៃប្រទេសអាស៊ានដែលមានសមាមាត្រ GDP ខ្ពស់នៃការនាំចេញទំនិញរួមមាន៖ សឹង្ហបុរី (១១០%) វៀតណាម(៩១%)និងម៉ាឡេស៊ី(៨៦%)។ ការនាំចេញទំនិញ គឺជាកំលាំងចលករដ៏សំខាន់ ចំពោះប្រទេសថៃទទួលបាន (៥៨%) និងសំរាប់ប្រទេសដែលមានទីផ្សារក្នុងស្រុកធំជាងដូចជា ប្រទេសឥណ្ឌូនេស៊ីទទួលបាន (២២%) និងប្រទេសហ្វីលីពីន(២០%)។ ការប្រើប្រាស់ត្រូវបានលើកកំពស់មួយផ្នែក ដោយសារតម្លៃទំនិញមានស្ថេរភាព និងរាល់សកម្មភាពដែលទាក់ទងទៅនឹងវិស័យទេសចរណ៍មានការកើនឡើង ទោះបីទទួលការប៉ះពាល់ខ្លះពីបរិស្ថានរូបិយវត្ថុតែបណ្តើង។ ការចំណាយខ្ពស់ជាងសំរាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធនានាក្នុងតំបន់ត្រូវបានរីកដុះដាល និងទទួលបានកំណើនខ្ពស់ ការស្តារឡើងវិញលើវិស័យនាំចេញ គឺជាផលវិជ្ជមានមួយដែលបញ្ជាក់ឲ្យឃើញថា វិស័យផលិតសំខាន់ៗផ្តើមងើបឡើងវិញ។ លើកលែងតែប្រទេសឡាវ តាមការព្យាករណ៍កំនើនសេដ្ឋកិច្ចគ្មានការផ្លាស់ប្តូរនៅក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥។

ចំពោះខឿនសេដ្ឋកិច្ចរបស់ប្រទេសឥណ្ឌូនេស៊ី តាមការព្យាករណ៍របស់ ADB បានឲ្យដឹងថា នឹងទទួលបានកំនើន ៥,០%នៅក្នុងឆ្នាំ២០២៤-២៥ តម្រូវការប្រើប្រាស់ក្នុងស្រុកនៅតែជាកំលាំងចលករដ៏សំខាន់សំរាប់ជួយទ្រទ្រង់ខឿនសេដ្ឋកិច្ចឲ្យទទួលបានកំណើន។ សេចក្តីត្រូវការរបស់ពលរដ្ឋកើន ជាផលល្អដល់ការចំណាយរបស់រដ្ឋ កាត់បន្ថយអតិផរណា និង បង្កើនប្រាក់ចំណូលដល់កម្មករ និយោជិក។ ចំពោះប្រទេសម៉ាឡេស៊ី ទទួលបានកំនើន ៤,៥% និង ៤,៦% សំរាប់ឆ្នាំ២០២៤ និង២០២៥ គឺគ្មានការផ្លាស់ប្តូរធៀបទៅនឹងការព្យាករណ៍មុន។ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤ GDP ទទួលកំនើន ៤,២% ដោយសារកំណើននៃការប្រើប្រាស់ខ្ពស់ ៤,៧% ជំរុញខ្លាំងក្លាវិស័យការងារ និងប្រាក់កំរៃ។ វិនិយោគទទួលបានកំណើនខ្ពស់ លើកទឹកចិត្តដល់ការវិនិយោគហេដ្ឋារចនាសម្ពន៍(១១,៩%) ការចំណាយសំរាប់គ្រឿងចក្រ និងគ្រឿងបន្លាស់(៨,៩%)។ ចំនួនភ្ញៀវទេសចរណ៍មានការកើនឡើងគួរឲ្យកត់សំគាល់(៣២%)ជាមួយនឹងកំនើនគេហដ្ឋានចរាចរអចលនៈទ្រព្យនិងវិស័យសាងសង់។ មានកាតកត់សំគាល់លើផ្នែកនាំចេញទំនិញមានការកើនឡើងយឺតយ៉ាវ២,៤%លើកលែងតែការនាំចេញឧស្ម័នធម្មជាតិ(៤,២%)និងផលិតផលប្រេងឆៅ(១៣,៣%)។ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ីគឺជាប្រទេសផលិតប្រេងដូងសំខាន់ពីរនៅអាស៊ីអាគ្នេយ៍ ហើយផ្គត់ផ្គង់ជិត ៩០% នៃបរិមាណផលិតផលសរុបពិភពលោក។ លើសពីនេះប្រទេសឥណ្ឌូនេស៊ីក៏ជាប្រទេសផលិតកាកាវធំទី៣ លើពិភពលោកផងដែរដោយធ្វើការផ្គត់ផ្គង់ប្រហែល ៤៥ម៉ឺនតោន/ឆ្នាំ ជាប្រទេសផលិតតែទី៨ លើពិភពលោក(ព័ត៌មានពីអង្គការស្បៀងអាហារ និងកសិកម្មពិភពលោក FAO)។ កំណើនសេដ្ឋកិច្ចរបស់ប្រទេសហ្វីលីពីន រក្សាដដែល ៦,០% សំរាប់ឆ្នាំ២០២៤ និង ៦,២% ឆ្នាំ២០២៥ ដោយសារតម្រូវ ការប្រើប្រាស់ក្នុងស្រុកការនាំចេញផលិតផលត្រូវបានស្តាឡើងវិញធ្វើឲ្យ GDP កើន ៥,៧% នៅក្នុងត្រីមាសទីមួយ ឆ្នាំ២០២៤។ ទោះបីជាកំណើននៃការប្រើប្រាស់តាមគ្រួសារទាបជាងឆ្នាំមុន ប៉ុន្តែនៅតែជាកំលាំងចលករដ៏សំខាន់ ដោយ សារភាគរយនៃចំនួនអ្នកគ្មានការងារធ្វើមានកំរិតទាប ប្រភពចំណូលពីកំលាំងពលកម្មនៅក្រៅប្រទេសខ្ពស់។ ការចំណាយខ្ពស់ទៅលើការកសាងហេដ្ឋារចនាសម្ពន្ធ័សាធារណៈបន្តជំរុញ និងបរិមាណទំនិញនាំចេញមានការកើនឡើង បូករួមទាំងអតិផរណាថយចុះ និងបូករួមទាំងការបើកទូលាយទីផ្សាររូបិយ័វត្ថុនៅចុងឆ្នាំ២០២៤ ដែលជាកំលាំងចលករជួយជំរុញតម្រូវការប្រើប្រាស់តាមគ្រួសារនីមួយៗ និងវិនិយោគកើនឡើង។ ប្រទេសហ្វីលីពីនជាប្រទេសផលិត និងនាំចេញដូង និងម្ចាស់ដ៏ធំមួយរបស់ពិភពលោក ហើយក៏ជាប្រទេសផលិតស្ករសដ៏ធំសំខាន់ផងដែរ យោងតាមទិន្នន័យដែលទើបប្រកាសដោយស្ថាប័នស្ថិតិ

ជាតិហ្វីលីពីននៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៤ ការនាំចេញទំនិញ និងសេវាកម្មរបស់ប្រទេសបានកើនឡើង៧,៥%។ រីឯប្រទេសសឹង្ហបុរី ទំហំផលិតផលក្នុងស្រុកសរុប (GDP) ទទួលបាន ២,៤% និងកើន ២,៧% ក្នុងត្រីមាសទីមួយឆ្នាំ ២០២៤ ដោយសារទទួលបានកំណើនខ្ពស់លើវិស័យសេវាកម្ម សំណង់រួមទាំងការនាំចេញ និងនាំចូល គឺមានការកើនឡើងខ្ពស់ ទោះបីជាការផលិតបានថយចុះក៏ដោយទំហំនាំចេញរបស់ប្រទេសសឹង្ហបុរី សម្រេចបានជាង ១៦៥,៩៤ពាន់លានដុល្លារសឹង្ហបុរី គឺកើនឡើង ៤,៤៥% ធៀបទៅនឹងរយៈពេលដូចគ្នានាឆ្នាំទៅ ដែលជាសមិទ្ធិផលពីការស្តារឡើងវិញនៃការនាំចេញ-នាំចូលខណៈដែលគោលនយោបាយរូបីយវត្ថុ ចរាចរក្នុងសេចក្តីសង្ឃឹមថាជាឥណទានងាយស្រួល និងអាចជំរុញកំណើនពាណិជ្ជកម្មតម្រូវការទំនិញអេឡិចត្រូនិចបានបង្កើនបរិមាណផ្គត់ផ្គង់លើវិស័យឧស្សាហកម្ម។

ការចំណាយទៅលើការប្រើប្រាស់ បានរួមចំណែកធ្វើឲ្យខឿនសេដ្ឋកិច្ចទទួលបានកំណើនខ្ពស់ បើទោះបីជាការវិនិយោគបានធ្លាក់ចុះបន្តិចក៏ដោយ ចំណែកការនាំចេញ-ចូល គឺមានការរីកចំរើនខ្លាំង ប៉ុន្តែមានការថយចុះធៀបត្រីមាសបន្ទាប់។ ទោះបីជានៅក្នុងវិស័យផលិតបានថយចុះនៅក្នុងត្រីមាសទី១ ប៉ុន្តែតួលេខ PMI បានឆ្លុះបញ្ចាំងឲ្យឃើញអំពីភាពរីកចំរើនរបស់សេដ្ឋកិច្ចពលរដ្ឋ។ វិស័យសេវាកម្មជាសេចក្តីសង្ឃឹមមុតមាំ បោះជំហ៊ានស្របជាមួយកំណើនតម្រូវការក្នុងស្រុក ការនាំចេញ និងបន្តរួមចំណែកធ្វើឲ្យខឿនសេដ្ឋកិច្ចប្រទេសនេះទទួលបានកំណើន បើទោះបីជាមានឧបសគ្គខ្លះៗអំពីតម្លៃទំនិញប្រើប្រាស់ និងអត្រាការប្រាក់ខ្ពស់។ ចំណែកឯកំណើនសេដ្ឋកិច្ចរបស់ប្រទេសថៃ ស្ថិតក្នុងកំរិត ២% នៅក្នុងឆ្នាំ២០២៤ និង ៣% ឆ្នាំ២០២៥ ដោយផ្អែកលើវិស័យទេសចរណ៍ និងតម្រូវការប្រើប្រាស់របស់ពលរដ្ឋ។ កំណើន នៃការប្រើប្រាស់របស់វិស័យឯកជន និងសេវាកម្មនានាជាប្រភពចំណូលសំខាន់ធ្វើឲ្យបេឡាចំណូលពីភ្ញៀវទេស-ចរណ៍មានការកើនឡើង។ ភាពជឿជាក់ទៅលើវិស័យប្រើប្រាស់ អាចនឹងមានការថយចុះ ដោយសារការកសាងគំរោងថ្មីៗ ជាពិសេសគំរោងកសាងផ្លូវរបៀងសេដ្ឋកិច្ចនៅភាគខាងកើតនៃប្រទេស តាមការព្យាករណ៍នឹងចាប់ផ្តើមនៅត្រីមាសទី៤ ឆ្នាំ២០២៤។ កំណើននៃការនាំចេញទំនិញ និងសេវាកម្មនឹងមានការកើនឡើងខ្ពស់នៅក្នុងឆ្នាំនេះ និងឆ្នាំខាងមុខបើគិតចាប់តាំងពីខែមករា ដល់ខែឧសភា ឆ្នាំ២០២៤ ទទួលបានភ្ញៀវទេសចរណ៍ចំនួន ១៤,៨លាននាក់។ ចំពោះកំណើនសេដ្ឋកិច្ចរបស់ប្រទេសវៀតណាម នៅក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ពុំមានការផ្លាស់ប្តូរ គឺ ៦,០% និង ៦,២% ខឿនសេដ្ឋកិច្ចបន្តស្តារឡើងវិញ ជាមួយនឹងកំរិតកំណើន ៦,៤% នៅពាក់កណ្តាលដើមឆ្នាំ២០២៤។ នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៤ ទំហំពាណិជ្ជកម្មនាំចេញទំនិញរបស់វៀតណាមត្រូវបានសន្និដ្ឋានថា នឹងឈានដល់ ៩៣,០៦ពាន់ លានដុល្លារអាមេរិក គឺកើនឡើងយ៉ាងខ្លាំង ជាពិសេសទំនិញកសិកម្ម រុក្ខាប្រមាញ់ និងជលផលទទួលបានចំនួន ៨,៤៦ពាន់លានដុល្លារ កើន ២៣,៨% និងផលិតផលឧស្សាហកម្មកែច្នៃ និងផលិតកម្មមានចំនួន ៧៩,៦ពាន់លានដុល្លារ ស្មើនឹង ៨៦% នៃទំហំនាំចេញសរុប។ ប្រេងឥន្ធនៈរ៉ែទទួលបានចំនួន ១,១៣ពាន់លានដុល្លារ កើន ១២,១% ធៀបឆ្នាំ២០២៣។ នៅក្នុងត្រីមាសទីមួយឆ្នាំ២០២៤ ឥណ្ឌូនេស៊ី គឺជាទីផ្សារនាំចូលធំទីបី របស់វៀតណាមក្នុងបណ្តាប្រទេសអាស៊ាន (បន្ទាប់ពីថៃ ២,៦ពាន់លានដុល្លារ និងម៉ាឡេស៊ី ២,៤១ពាន់លានដុល្លារ)។ ជាលើកដំបូងវៀតណាមបានក្លាយជាប្រទេសនាំចេញអង្ករធំជាងគេទៅកាន់ទីផ្សារសឹង្ហបុរី និងជាដៃគូរនាំចេញទំនិញដល់ផលធំទី៥។ ការនាំចេញគ្រឿងអេឡិចត្រូនិចកំពុងនាំមុខគេក្នុងការស្តារឡើងវិញនៃវិស័យពាណិជ្ជកម្ម ហើយមួយចំណែកធំការនាំចេញពីប្រទេសហ្វីលី-ពីន ម៉ាឡេស៊ី វៀតណាម និងសឹង្ហបុរី គឺបានមកពីប្រទេសថៃ។

កសិកម្មនៅតែជាវិស័យដ៏សំខាន់បំផុតមួយសម្រាប់បណ្តាប្រទេសនៅតំបន់អាស៊ីអគ្នេយ៍ គឺទទួលបានខ្ពស់ជាង ២៥% នៃផលិតផលក្នុងស្រុកសរុប(GDP) របស់ប្រទេសអាស៊ានមួយចំនួន។ សម្រាប់ប្រទេសមីយ៉ាន់ម៉ា វិស័យនេះបង្កើតការងារច្រើនជាង ៤០% នៃតួរលេខសរុប។ អាស៊ានជាប្រភពផ្គត់ផ្គង់កសិផលសំខាន់សម្រាប់ទីផ្សារធំៗជាច្រើនលើពិភពលោក។ ឥណ្ឌូនេស៊ី ថៃ និងម៉ាឡេស៊ី ដំណាំកៅស៊ូប្រហែល ៣,៣លានតោន/ឆ្នាំ ដែលស្មើនឹង ៧០% នៃបរិមាណផលិតផលពិភពលោក។ សេចក្តីសង្ឃឹមអំពីអនាគតនៃការនាំចេញរបស់អាស៊ាននឹងកើនឡើងវិញ និងជួយពង្រីកអតិពាណិជ្ជកម្ម បង្កើនការទុកបម្រុងរូបីយវត្ថុបរទេស និងរក្សាស្ថិរភាពរូបីយ៍បណ្ណ័ក្នុងស្រុក កំណែទំរង់គោលនយោបាយថវិកាជំរុញឲ្យខឿនសេដ្ឋកិច្ចអាស៊ានឈានឡើងខ្ពស់។

ប្រភព៖ Website Vinanet

# អំពីព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម

ព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម គឺជាព្រឹត្តិបត្របោះពុម្ពផ្សាយដោយនាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។ ព្រឹត្តិបត្រនេះប្រមូលផ្តុំនូវមាតិកាសំខាន់ៗរួមមាន ស្ថិតិព័ត៌មានពាណិជ្ជកម្ម សន្ទស្សន៍ថ្លៃទំនិញចាំបាច់ ព័ត៌មានតម្លៃទំនិញសំខាន់ៗ លើទីផ្សារពិភពលោក និងអត្ថបទស្រាវជ្រាវ។

## សមាសភាពថ្នាក់ដឹកនាំ និងក្រុមការងារ

១- ឯកឧត្តម ប៉ែន សុវិជាតិ

២- លោកជំទាវ សេរី បូរាពេជ្រ

៣- លោក គន់ ឌីរ៉ង់

៤- លោកស្រី ឡុង លាបភា

៥- លោកស្រី ធន សាល័ក្ខណ៍

៦- លោកស្រី ចាំច់ ម៉ារីយ៉ា

៧- លោក យឹម រ៉ុម

៨- លោក ស៊ិន សុខហេង

៩- លោក សេង សុគន្ធា (អ្នករចនា)

## សូមស្កេន QR Code ដើម្បីភ្ជាប់ទៅ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម

Website
www.moc.gov.kh

Facebook
@moc.gov.kh

Telegram
@mocnewsfeed

YouTube
@mocgovkhcambodia

X Account
@MoCCambodia


ដីឡូត៍ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣ បេ) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ ១២១០២

Lot 19-61 MOC Road (113B Road) Phum Teuk Thla , Sangkat Teuk Thla , Khan Sen Sok, Phnom Penh 12102

Email : dpsti.bulletin@moc.gov.kh